# II - រាជរដ្ឋាភិបាល

## ១_អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

### អនុក្រឹត្យ លេខ ១៥ អនក្រ.បក
### ស្តីពីការបង្កើតមន្ទីរពិសោធន៍សំណង់ និង
### សាធារណការ (ម.ព.ស.ស)

***

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស្.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស រកត ១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ១៩៩៤ និងព្រះព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស រកត ១០៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រម លេខ នស រកម ១០៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រម លេខ ជស.រកម.០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- តាមសំណើរួមរបស់ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងទេសរដ្ឋមន្ត្រីទទួលបន្ទុកនីតិសម្បទា និងអភិវឌ្ឍន៍ និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គណៈរដ្ឋមន្ត្រីយល់ព្រមផង

## សម្រេច

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**មាត្រា១ :** មន្ទីរពិសោធន៍សំណង់ និងសាធារណការ (ម.ព.ស.ស) ត្រូវបានទទួលលក្ខណៈសម្បត្តិជាគ្រឹះស្ថានសាធារណៈមួយមានឧបនិស្ស័យសេដ្ឋកិច្ច តាមន័យរបស់មាត្រា២៦ នៃព្រះរាជក្រម លេខ ០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាស សាធារណៈ ។ ម.ព.ស.ស ជានីតិបុគ្គល ប្រកបដោយស្វ័យភាពផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ស្ថិតនៅក្រោមអាណាព្យាបាល បច្ចេកទេស នៃក្រសួងសាធារណការនិងដឹកជញ្ជូន ។

ម.ព.ស.ស ស្ថិតនៅក្រោមឥទ្ធិពលបទបញ្ញត្តិនៃអនុក្រឹត្យនេះ ហើយក្នុងករណីដែលអនុក្រឹត្យនេះពុំបានបញ្ជាក់ ការគ្រប់គ្រងនៃ ម.ព.ស.ស ត្រូវគោរពតាមបទបញ្ញត្តិ នៃព្រះរាជក្រមលេខ ០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ព្រមទាំងបទបញ្ញត្តិនៃច្បាប់ពាណិជ្ជកម្ម។

**មាត្រា២ :** ម.ព.ស.ស មានបេសកកម្ម ៖

- ធ្វើការស្រាវជ្រាវរកបច្ចេកទេសថ្មីៗ សំដៅកែលំអគំរោងសំណង់ទាំងឡាយ ព្រមទាំងចូលរួមក្នុងការតាក់តែងបទដ្ឋានពិសេសសំរាប់ប្រទេសកម្ពុជា ក្នុងវិស័យសិក្សាស្រាវជ្រាវបច្ចេកទេសសំណង់ ។
- ធ្វើការសិក្សាពិសេស ចំពោះមេកានិកដី ចំពោះសំភារៈសំណង់សំរាប់ជកស្រង់ទិន្នន័យចាំបាច់ក្នុងការរៀបចំគំរោងសំដៅទិដ្ឋភាពពីរ គឺសុវត្ថិភាព និងការសន្សំសំចៃ ។

- គ្រួតពិនិត្យគុណភាពសំភារៈសំណង់ និងការប្រើប្រាស់សំភារៈនោះ ។
- តាមដានការងារ មិនត្រឹមតែក្នុងរយៈពេលសាងសង់ទេ ប៉ុន្តែបន្តទៅក្នុងពេលធ្វើអាជីវកម្មប្រើប្រាស់សំណង់ ក្នុងគោលដៅបង្កើនទិន្នផលបច្ចេកទេស ។
- ធ្វើការណែនាំផ្តល់យោបល់ និងផ្តល់ជំនួយបច្ចេកទេស កោសល្យវិច័យ ពិនិត្យការខុសឆ្គង ក្នុងផ្នែកសំណង់ ។
- ធ្វើសហប្រតិបត្តិការ ដើម្បីការបង្ហាត់បង្រៀនបច្ចេកទេសគ្រប់មុខវិជ្ជាទាក់ទិននឹងវិស័យសំណង់ ។
- ទទួលកម្មសិក្សាការី បណ្តុះបណ្តាលអ្នកបច្ចេកទេស រៀបចំថ្នាក់បង្រៀនឯកទេសរួមជាមួយ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ។
- រៀបចំរោរណាបច្ចេកទេស ដោយប្រមូលផ្តុំនូវទិន្នន័យគ្រប់វិស័យដែលខ្លួនទទួលបានពេលប្រកបសកម្មភាពការងាររបស់ខ្លួន ។

**មាត្រា ៣** : ម.ព.ស.ស មានភារកិច្ចទទួលយកមកធ្វើការពិសោធន៍ ការសិក្សា ឬការស្រាវជ្រាវនូវគ្រប់សំណើទាំងអស់ ទោះម្ចាស់សំណើជាឯកជន ឬជាស្ថាប័នសាធារណៈអោយតែសំណើស្របនឹងបេសកកម្ម របស់ខ្លួន ដូចមានចែងក្នុងមាត្រា២ ខាងលើ ។

កិច្ចការទាំងនោះត្រូវគិតជាតំលៃសេវា ដូចដែលមានចែងក្នុងមាត្រា២០ខាងក្រោម ។ បើមានសំណើច្រើន ម.ព.ស.ស ត្រូវអនុវត្តតាមលំដាប់អាទិភាពដែលតំរូវដោយក្រសួងសាធារណការនិងដឹកជញ្ជូន ។

ស្ថាប័នរដ្ឋ និង សហគ្រាសសាធារណៈទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាដែលប្រើប្រាស់ទុនថវិការដ្ឋក្នុងការងារសាងសង់ត្រូវផ្តល់អាទិភាពអោយ ម.ព.ស.ស នូវកិច្ចការពិសោធន៍ ការសិក្សា ការស្រាវជ្រាវដែលចូលទៅក្នុងបរិវេណនៃបេសកកម្ម និងបច្ចេកទេសរបស់ ម.ព.ស.ស ។

**មាត្រា៤** : ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ម.ព.ស.ស ត្រូវប្រកាន់គោលការណ៍ និង របៀបប្រកបកិច្ចការដូចគ្នា និង ពាណិជ្ជកម្មទូទៅ ។ ក្នុងន័យនេះ ម.ព.ស.ស ត្រូវទទួលស្វ័យតភាពយ៉ាងធំទូលាយ ដើម្បីដឹកនាំចាត់ចែងសកម្មភាពរបស់ខ្លួនក្នុងគោលដៅបំពេញបេសកកម្មអោយមានប្រសិទ្ធភាព និងធ្វើយ៉ាងណាអោយបេតិកភ័ណ្ឌរបស់ខ្លួនបានគង់វង់ និងមានការរីកចំរើន ។

**មាត្រា ៥ :** ម.ព.ស.ស ត្រូវបង់ពន្ធអាករទាំងឡាយស្របតាមច្បាប់ និងបទបញ្ញាជាធរមាន ។

## ជំពូកទី២

## រចនាសម្ព័ន្ធ និងរដ្ឋបាល

**មាត្រា៦ :** ម.ព.ស.សត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល ដែលមានសមាសភាពដូចខាងក្រោម:

- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន ១រូប.................... ប្រធាន
- តំណាងក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ១រូប.................... សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ រូប.................... – ជ –
- តំណាងសាលាក្រុងភ្នំពេញ ១ រូប.................... – ជ –
- តំណាងសហជីពនៃសហគ្រាសអាគារ និងសាធារណការ ១រូប...... – ជ –
- នាយកសំណង់អាគារ និងនគរូបនីយកម្ម.................... – ជ –
- នាយក ម.ព.ស.ស.................... – ជ –

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវចាំបាច់តែងតាំងដោយអនុក្រឹត្យតាមសំណើនៃក្រសួង ឬ អាជ្ញាធរដែលខ្លួនតំណាងអោយ ។

**មាត្រា៧ :** សមាជិកក្រុមប្រឹក្សាភិបាល ត្រូវមានសញ្ជាតិខ្មែរ មានសិទ្ធិរដ្ឋប្បវេណីពេញលេញ ពុំដែលទទួលទណ្ឌកម្មមានកំរិតធ្ងន់ពីតុលាការឡើយ ។ លើសពីនេះទៅទៀត សមាជិកក្រុមប្រឹក្សាទាំងនោះ ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីសកម្ម ដែលបានបំរើការយ៉ាងតិច៥ឆ្នាំ ឬឥស្សរជនពុំមែនជាមន្ត្រី រាជការដែលមានអាយុមិនលើសពី៦៥ឆ្នាំ តែមានម[illegible]ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រសាងសង់ ។

អាណត្តិសមាជិកក្រុមប្រឹក្សាភិបាល មានថេរវេលា៣ឆ្នាំ ហើយថេរវេលានេះអាចបន្តជាថ្មីទៀតបាន។

ក្នុងការបំពេញអាណត្តិរបស់ខ្លួន សមាជិកក្រុមប្រឹក្សាភិបាល ពុំទទួលការខុសត្រូវផ្ទាល់ខ្លួនម្នាក់ៗ ឬការទទួលខុសត្រូវរួមគ្នាទេ ។ ក្នុងករណីដែលសមាជិកណាម្នាក់មានកំហុសធ្ងន់ធ្ងរ សមាជិករូបនោះអាចត្រូវដកចេញពីមុខងាររបស់ខ្លួនគ្រប់ពេលវេលាដោយអនុក្រឹត្យ ។

**មាត្រា៨ :** ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសំរេចក្នុងនាមនៃម. ព. ស. សនិងដើម្បីបំពេញ ឬអនុញ្ញាតលិខិត និងឯកសារគ្រប់ជំពូកទាក់ទងនឹងកម្មវត្ថុរបស់ ម. ព. ស. ស ស្របតាមច្បាប់ជាធរមាន។

ជាអាទិ ក្រុមប្រឹក្សាភិបាលមានភារកិច្ច ÷

១–ផ្តល់ការយល់ព្រមលើគំរោងថវិកាប្រចាំឆ្នាំ សំរាប់ដំណើរការនៃមន្ទីរពិសោធន៍ និងសំរាប់ការវិនិយោគ ស្របតាមកម្មវិធីនៃសកម្មភាព ។

២–ផ្តល់ការយល់ព្រមលើតុល្យការ និងគណនីប្រចាំឆ្នាំ ព្រមទាំងលើរបាយការណ៍សកម្ម ភាពរបស់សហគ្រាស ។

៣–សំរេចតាមសំណើនៃនាយកឲ្យរចនាសម្ព័ន្ធ និងបទបញ្ជាផ្ទៃក្នុង ព្រមទាំងលក្ខន្តិកៈ និង ការប្រាក់បៀវត្សសំរាប់បុគ្គលិក ដោយគោរពច្បាប់ និងបទបញ្ញត្តិទាំងឡាយជាធរមាន ។

៤–ផ្តល់ការយល់ព្រមលើកិច្ចសន្យា និងអនុសញ្ញាដែលចុះដោយសហគ្រាសសាធារណៈ។

៥–កំណត់លក្ខខណ្ឌ និងនីតិវិធីសំរាប់ការទទួលជំនួយបច្ចេកទេសពីអង្គភាពក្នុងស្រុក ឬបរទេស ។

៦–ផ្តល់ការយល់ព្រមលើកម្មវិធីពហុឆ្នាំ សំរាប់សំភារៈ និងបរិក្ខារ ។

៧–កំណត់តំលៃសេវាកម្ម និងការងារផ្សេងៗ ។

៨–កំណត់កម្មវិធីពហុឆ្នាំ នៃការស្រាវជ្រាវ និងកំណត់ឥណទានសំរាប់ការងារទាំងនេះ ។

៩–អនុញ្ញាតអោយលក់ ទិញ ជួញដូរអចលនទ្រព្យគ្រប់ប្រភេទ ឬភាគហ៊ុន ព្រមទាំងអនុញ្ញាតការខ្ចីបុលអំឡុងកាលមធ្យម ឬវែងដោយ ម. ព. ស. ស ស្របតាមច្បាប់ និងបទបញ្ជាទាំង ឡាយជាធរមាន ។

១០–សំរេចបង្កើតបើក បិទការិយាល័យ និងទីភ្នាក់ងារគ្រប់ទីកន្លែងតាមការវិនិយោគរបស់ខ្លួន ។

១១–កំណត់បែបបទនៃការជួយឧបត្ថម្ភដល់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ។

**មាត្រា៩ :** ក្រុមប្រឹក្សាភិបាលបើកប្រជុំរាល់ៗវេលា អាស្រ័យតាមតំរូវការនៃ ម. ព. ស. ស តាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើនៃសមាជិកដែលមានចំនួនបួន (៤) នាក់

យ៉ាងតិចក្នុងបណ្តាសមាជិកទាំងអស់ ។ ទោះយ៉ាងណាក៏ដោយកិច្ចប្រជុំត្រូវធ្វើឡើង យ៉ាងតិចមួយដង ក្នុងរយៈពេល៣ខែ ។

ប្រធានដែលជាប់ធុរៈ ត្រូវជ្រើសរើសសមាជិកម្នាក់ក្នុងបណ្តាសមាជិកក្រុមប្រឹក្សាភិបាល សំរាប់បំពេញភារកិច្ច ជំនួសប្រធានជាបណ្តោះអាសន្ន ។ ក្រុមប្រឹក្សាភិបាលពិភាក្សាលើបញ្ហាទាំងឡាយ ដែលចូលក្នុងក្របខ័ណ្ឌនៃតួនាទីរបស់ខ្លួន ។

**មាត្រា១០ :** របៀបវារៈ នៃការប្រជុំ ព្រមទាំងឯកសារទាក់ទិនទាំងឡាយ ត្រូវផ្ញើទៅជូនសមាជិកក្រុម ប្រឹក្សាភិបាលគ្រប់រូបអោយបានយ៉ាងតិច១០ថ្ងៃមុនពេលបើកអង្គប្រជុំ ។

កិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តបាន លុះត្រាតែចំនួនសមាជិកវត្តមានក្នុងសម័យប្រជុំនោះ មានចំនួនយ៉ាងតិចពាក់កណ្តាលបូកមួយ នៃបណ្តាសមាជិកទាំងអស់ ។ បើសិនជាចំនួនកូរ៉ុម មិនបានគ្រប់ទេ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំជាថ្មីម្តងទៀត ក្នុងរយៈពេល១៥ថ្ងៃក្រោយ ដើម្បីពិភាក្សាសំរេចឡើងវិញ លើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះមិនទាមទារកូរ៉ុមទេ ។

សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំលេងភាគច្រើន នៃសមាជិកវត្តមាននៅក្នុងអង្គប្រជុំ ។ បើសិនការចែកសំលេងមានចំនួនស្មើ ពុំអាចដាច់ស្រេចបាន សំលេងប្រធានមានអាទិភាពលើសំលេងសមាជិកដទៃទៀត ។

**មាត្រា១១ :** សេចក្តីសំរេចនៃក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាល ទៅសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និង «មន្ត្រីត្រួតពិនិត្យរដ្ឋ» ព្រមទាំងស្ថាប័នដ៏ទៃទៀត ដែលមានចែងក្នុងមាត្រា២៣ ក្នុងរវាង១៥ថ្ងៃយ៉ាងយូរ ចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុនៃកិច្ចប្រជុំ ត្រូវទទួលការយល់ព្រមពីក្រុមប្រឹក្សាភិបាលនាសម័យប្រជុំលើកក្រោយ ហើយត្រូវចំលងចូលបញ្ជីដែលមានលេខរៀងទំព័រជាហូរហែ និងមានហត្ថលេខាចំណាំត្រឹមត្រូវ ។ កំណត់ហេតុដើម ត្រូវមានចុះហត្ថលេខាដោយប្រធាននៃអង្គប្រជុំ និងសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ ដែលមានវត្តមានក្នុងកិច្ចប្រជុំពេលមុននោះ ។

**មាត្រា១២** : ការគ្រប់គ្រងជាប្រក្រតី នៃ ម.ព.ស.ស ត្រូវប្រគល់ទៅនាយកមួយរូប ដែលស្ថិតនៅក្រោមនិវាទនៃក្រុមប្រឹក្សាភិបាល ។ នាយក ម.ព.ស.ស ត្រូវតែងតាំងសំរាប់អាណត្តិ៣ឆ្នាំ ដោយអនុក្រឹត្យ តាមសំណើនៃរដ្ឋមន្ត្រីអាណាព្យាបាល ។

**មាត្រា១៣** : ក្រុមប្រឹក្សាភិបាលប្រគល់ជូននាយក នូវអំណាចចាំបាច់សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់សំរាប់ដឹកនាំ ម.ព.ស.ស ស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

ក្នុងក្របខ័ណ្ឌនេះនាយក ÷

១- ជាអ្នករៀបចំសំណុំរឿងទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលសំរេច និងជាអ្នកចាត់ចែងការអនុវត្តន៍រាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។ តាមកំណត់ពេលនិមួយៗ នាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល អំពីសកម្មភាពរបស់ ម.ព.ស.ស ។

២- ទទួលបន្ទុកដឹកនាំ ម.ព.ស.ស ផ្នែកបច្ចេកទេស រដ្ឋបាល និងហិរញ្ញវត្ថុ ។

៣- តំណាង ម.ព.ស.ស ចំពោះមុខតតិយជនទាំងឡាយ ក្នុងការបំពេញលិខិតស្នាមស៊ីវិល រដ្ឋបាល ឬលិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និង ការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៤- មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតតំណែង ឬបញ្ឈប់ពីការងារ មានសិទ្ធិបញ្ជាត្រួតត្រានូវភ្នាក់ងារ ឬមន្ត្រីគ្រប់រូប ដែលជានិយោជិតរបស់ ម.ព.ស.ស ដោយគោរពតាមបទបញ្ញត្តិលក្ខន្តិកៈបុគ្គលិក តាមច្បាប់ជាធរមាន និង តាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥- មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ ព្រមទាំងផ្ទេរសិទ្ធិចុះហត្ថលេខាទៅអោយមន្ត្រី ដែលធ្វើការក្រោមនិវាទខ្លួន ស្របតាមលក្ខខ័ណ្ឌដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៦- ជាសរុប នាយកជាអ្នកអនុវត្តនូវគ្រប់ភារកិច្ច ដែលក្រុមប្រឹក្សាភិបាលប្រគល់អោយ ។

**មាត្រា១៤** : លាភការរបស់នាយក និងប្រាក់បំណាច់សំរាប់សមាជិកក្រុមប្រឹក្សាភិបាលត្រូវកំណត់ដោយក្រសួងអាណាព្យាបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា១៥ :** ការចុះ និងការអនុវត្តន៍កិច្ចសន្យាដោយ ម.ព.ស.ស ត្រូវគោរពតាមបែបបទ និងនីតិវិធី ដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូកទី៣

### លក្ខន្តិកៈ នៃបុគ្គលិក

**មាត្រា១៦ :** ក្រៅពីនាយក បុគ្គលិករបស់ម.ព.ស.ស ស្ថិតនៅក្រោមបទបញ្ញត្តិនៃលក្ខន្តិកៈដោយឡែក មួយដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ។

ទំរាំមានលក្ខន្តិកៈដោយឡែកនេះ ក្រុមប្រឹក្សាភិបាលត្រូវសំរេចអំពីអន្តរវិធានដែលទាក់ទងនឹងបញ្ហានេះនៅក្នុងកិច្ចប្រជុំលើកទី១របស់ខ្លួនដើម្បីអោយ ម.ព.ស.ស អាចមានដំណើរការ ប្រព្រឹត្តទៅ ។

ចាប់ពីពេលដែលលក្ខន្តិកៈដោយឡែកនេះ បានចូលជាធរមានបុគ្គលិករបស់ ម.ព.ស.ស លែងមានលក្ខណៈសម្បត្តិជាមន្ត្រីរាជការរបស់រដ្ឋតទៅទៀត ។

បន្ថែមលើបុគ្គលិកអចិន្ត្រៃយ៍ម.ព.ស.ស អាចជ្រើសបុគ្គលិកជាប់កិច្ចសន្យា ឬបុគ្គលិកអណ្តែតដើម្បី បំពេញកិច្ចការដែលមានភាពមិនខ្ជាប់ខ្ជួន ។

ម.ព.ស.ស អាចទទួលនិស្សិតនៃសាលាសាធារណការ និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ឬភ្នាក់ងាររាជការដទៃទៀត ជាកម្មសិក្សាការី ។ ភ្នាក់ងារ និងនិស្សិតទាំងនេះ បន្តបើកប្រាក់បៀវត្សពីអង្គភាពដើមរបស់ខ្លួនដដែល ។

## ជំពូកទី៤

### ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា ១៧ :** ម.ព.ស.ស កាន់គណនេយ្យរបស់ខ្លួន ដោយប្រើតួលេខស្របតាមបទបញ្ជាគណនេយ្យកម្ពុជា និងតាមវិធានការនៃគណនេយ្យដែលគេទទួលស្គាល់ជាទូទៅ ។ រយៈកាលិយបរិច្ឆេទ គណនេយ្យ ចាប់ផ្តើមពីថ្ងៃទី១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ធ្នូនៃឆ្នាំដដែល ។

តុល្យការ និងគណនីគ្រប់ គ្រងត្រូវកំណត់ទូទាត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី៣០ ខែមីនា នៃឆ្នាំបន្ទាប់បិទកាលិយច្ឆេទ ឈរលើរបាយការណ៍ នៃគណនេយ្យករជំនាញម្នាក់ដែលមានមុខងារជាស្នងការគណនី ។

គុណ្យការគណនីគ្រប់គ្រងព្រមទាំងរបាយការណ៍ របស់ស្នងការគណនីត្រូវដាក់សុំការយល់ព្រមអំពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងអំឡុងវេលាមិនលើសពី១៥ថ្ងៃរាប់ពីថ្ងៃ ដែលក្រុមប្រឹក្សាភិបាលបានពិនិត្យឯកសារទាំងឡាយ ។ ឯកសារទាំងនេះក៏ត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលផងដែរ ដើម្បីសុំមតិទៅតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា១៦ នៃព្រះរាជក្រមលេខ ០៦៩៦/០៣ ចុះថ្ងៃទី១៧ មិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈ នៃសហគ្រាសសាធារណៈ ។

**មាត្រា១៨ :** ស្នងការគណនីត្រូវតែងតាំងដោយក្រុមប្រឹក្សាភិបាលសំរាប់អាណត្តិ២ឆ្នាំ។ ថេរវេលានេះអាចបន្តទៀតបាន ។ ប្រាក់បំណាច់សំរាប់ស្នងការគណនីត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល ហើយត្រូវចាត់ទុកជាចំណាយអាជីវកម្មរបស់ ម.ព.ស.ស ។ ស្នងការគណនីត្រូវធ្វើរបាយការណ៍មួយ ដើម្បីបញ្ជាក់ថា គណនីប្រចាំឆ្នាំនៃការិយបរិច្ឆេទ មានភាពស្មោះត្រង់ និងត្រឹមត្រូវល្អ ហើយឆ្លុះបញ្ចាំងអំពីភាព ពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុ និងបេតិកភណ្ឌរបស់ ម.ព.ស.ស ។

នៅគ្រប់វេលា ស្នងការ គណនី អាចធ្វើការឆែកឆេរ និងការត្រួតពិនិត្យដែលខ្លួនយល់ថា ចាំបាច់គួរតែត្រួតពិនិត្យថែមទាំងអាចទារឯកសារ និង បញ្ជីគណនេយ្យគ្រប់យ៉ាងសំរាប់ធ្វើការត្រួតពិនិត្យ ។ បើការពិនិត្យស្រាវជ្រាវនេះបង្ហាញអោយឃើញភាពមិនត្រឹមត្រូវណាមួយ ស្នងការគណនីត្រូវរាយការណ៍ភ្លាមជូនប្រធានក្រុមប្រឹក្សាភិបាល ។ ស្នងការគណនីអាចចូលប្រជុំជាមួយក្រុមប្រឹក្សាភិបាល បានតាមសេចក្តីអញ្ជើញនៃ ប្រធានក្រុមប្រឹក្សាភិបាល ។

**មាត្រា១៩ :** រៀងរាល់ឆ្នាំ មុនថ្ងៃ១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគំរោងប្រចាំឆ្នាំ នៃម.ព.ស.ស តាមសំណើរបស់នាយក ហើយបញ្ជូនគំរោងនេះ ដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីអាណាព្យាបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ គំរោងប្រចាំឆ្នាំនេះ ត្រូវបញ្ជាក់នូវ ÷

១–កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបំរុងសំរាប់កម្មវិធីវិនិយោគនេះ ។

២–ថវិកាសំរាប់ដំណើរការនៃម.ព.ស.ស ។

៣–តំលៃផ្តល់សេវាកម្មផ្សេងៗរបស់ម.ព.ស.ស ទៅអតិថិជន ដើម្បីខ្លួនមានលទ្ធភាពទប់ ទល់នឹងសោហ៊ុយ ។

៤-លក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងលទ្ធផលសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ ម.ព.ស.ស ។

## ជំពូកទី៥

### ធនធានរបស់ ម.ព.ស.ស

**មាត្រា ២០:** ពេលអនុក្រឹត្យនេះចូលជាធរមាន អាគារម.ព.ស.ស កំពុងប្រើប្រាស់ ត្រូវ... ដើមទុនដំបូង ។ ហើយត្រូវគិតគូរយ៉ាងណាកុំអោយ ម.ព.ស.ស មានឱនភាព ។ ចំណាយសំរាប់ជួសជុល និងថែរក្សាអាគារនេះជាចំណាយប្រក្រតីនៃម.ព.ស.ស ។ ម.ព.ស.ស អាចនឹងទទួលជំនួយពីបរទេសសំរាប់ពង្រឹង និង ពង្រីកដំណើរការ អាជីវកម្មរបស់ខ្លួន ។

សំភារៈដែលម.ព.ស.ស កំពុងប្រើប្រាស់ត្រូវកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌមួយ ហើយទុកជាសម្បត្តិផ្ទាល់ របស់ម.ព.ស.ស ។

ចំណូលប្រក្រតីរបស់ម.ព.ស.ស បានមកពីតំលៃសេវា ដែលខ្លួនផ្តល់ អោយ អតិថិជន ។ តារាងតំលៃសេវាត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល តាមសំណើ របស់នាយក ។ ហើយត្រូវគិតគូរយ៉ាងណាកុំអោយ ម.ព.ស.ស មានឱនភាព ។

**មាត្រា២១ :** ម.ព.ស.ស អាចមានគណនីចរន្តក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់ គណនី នេះសំរាប់តំរូវការរបស់ខ្លួន ។

**មាត្រា២២ :** ការខ្ចីបុល អំឡុងកាលមធ្យមឬវែងដោយ ម.ព.ស.ស សំរាប់ប្រើប្រាស់លើចំណាយ វិនិយោគ ត្រូវមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី៦

### ការទំនាក់ទំនងជាមួយរដ្ឋ

**មាត្រា២៣ :** ១៥ថ្ងៃយ៉ាងយូរបំផុត ក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល ម.ព.ស.ស ត្រូវ ផ្ញើជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីអាណាព្យាបាល និងរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នូវឯកសារដូចខាងក្រោមនេះ ÷

-កំណត់ហេតុ នៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនីមួយៗ

-គំរោងប្រចាំឆ្នាំ ដូចមានចែងក្នុងមាត្រា ១៩នៃអនុក្រឹត្យនេះ

–របាយការណ៍ ស្ដីពីសកម្មភាព គុណភាព និងគណនីគ្រប់គ្រងទាំងឡាយនៃ ម.ព.ស.ស

–របាយការណ៍ ស្ដីពីការ[illegible]

**មាត្រា២៤ :** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្នើរផ្ដាក់ចាលតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ ម្នាក់អម ម.ព.ស.ស ។ មន្ត្រីរូបនេះ ចូលរួមគ្រប់កិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាល ហើយអាចផ្ដល់យោបល់លើគ្រប់ចំណុចទាំងឡាយ ដែលមានក្នុងរបៀបវារៈ តែពុំមានសំលេងឆ្នោតទេ ។ «មន្ត្រីត្រួតពិនិត្យរដ្ឋ» បំពេញបេសកកម្មរបស់ខ្លួនអនុលោមតាមបទបញ្ញត្តិ នៃមាត្រា២០ ទៅ២៥ នៃព្រះរាជក្រមលេខ ០៦៩៦/ ០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្ដីពីលក្ខន្តិកៈរួមនៃសហគ្រាសសាធារណៈ ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា២៥:** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងប្រធានស្ថាប័នដែលមានការពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ព្រះហស្តលេខា និងត្រា ហត្ថលេខា និងត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

បានបង្គំទូលថ្វាយ និងជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រីទី១ និង ទី២

ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន

ហត្ថលេខា

**អ៊ឹង គៀត**

ទេសរដ្ឋមន្ត្រីទទួលបន្ទុកនីតិសម្បទា និងអភិវឌ្ឍន៍ និងជារដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

**គាត ឈន់**

* * *